global witness

**EMBARGOED:** 00:01 GMT+7, 11th May 2010

យើងបានភ្ជាប់នូវច្បាប់ដែលបានបកប្រែជាភាសាខ្មែរនៃឯកសារនេះ ។ ដើម្បីចៀសវាងចម្ងល់ ក្នុងករណីដែលមានភាពប្រទើសដោយភាពមិនច្បាស់លាស់នៃអត្ថន័យ ឬអ្វីៗផ្សេងៗទៀត
សេចក្តីប្រកាសពតិមានជាភាសាអង់គ្លេសនឹងត្រូវបាន យកជាឯកសារដើម ហើយចម្ងល់នានាទាក់ទងនឹងការបកប្រែគួរតែត្រូវបានកំណត់ដោយការយោងមកសំណៅមួយនេះ ប៉ុណ្ណោះ ។

## Global Witness បានបញ្ចេញរបាយការណ៍ថ្មីមួយបង្ហាញថា បរិស្ថានកំពុងមានគ្រោះថ្នាក់ ដោយសារប្រទេសកម្ពុជានាំចេញខ្សាច់ រាប់លានតោនទៅកាន់ប្រទេសសិង្ហបុរី

តាមរបាយការណ៍ថ្មីមួយដែលចេញផ្សាយថ្ងៃនេះដោយអង្គការ **Global Witness** បានឱ្យដឹងថា ការរីកចម្រើនយ៉ាងឆាប់រហ័សរបស់**ប្រទេសសិង្ហបុរី** កំពុងនាំឱ្យមានការបំផ្លិចបំផ្លាញផ្នែកអេកូឡូហ្ស៊ី និងសង្គម តាមរយៈឧស្សាហកម្មបូមខ្សាច់នៅក្នុងប្រទេសកម្ពុជា។ ពាណិជ្ជកម្មរីកចម្រើននេះ កំពុងត្រូវបានផ្តាច់មុខដោយព្រឹទ្ធសមាជិកខ្មែរល្បីល្បាញពីររូប ដែលមានទំនាក់ទំនងយ៉ាង ជិតស្និទ្ធជាមួយនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន - បើទោះបីជារដ្ឋាភិបាល បានហាមការនាំចេញខ្សាច់ក៏ដោយ។

*របាយការណ៍អង្គការ* **Global Witness** *ស្តីពីការផ្ទេរខ្សាច់ : សេចក្តីត្រូវការខ្សាច់របស់**ប្រទេសសិង្ហបុរីពីប្រទេសកម្ពុជា** កំពុងតែគំរាមកំហែងដល់ប្រព័ន្ធអេកូឡូហ្ស៊ី និងធ្វើឱ្យអន្តរាយដល់អភិបាលកិច្ចល្អ* បង្ហាញឱ្យឃើញថា :

- ព្រឹទ្ធសមាជិកខ្មែរ ឧកញ៉ាម៉ុង ឬទ្ធី និង ឧកញ្ញាលី យ៉ុង ផាត់ បានទទួលអាជ្ញាប័ណ្ណប្រមូលយកធនធានខ្សាច់ដោយសម្ងាត់ព្រមទាំងទទួលបាននូវការគ្រប់គ្រងឧស្សាហកម្មមួយដែលមានតម្លៃរាប់លានដុល្លារ - តែមិនមានភស្តុតាងស្តីពីប្រាក់ចំណូលណាមួយបានទៅដល់ហិបថវិការរបស់ប្រទេសកម្ពុជាឡើយ។ អ្នកឧកញ៉ាទាំងពីរ បានជាប់ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងអំពីដីដ៏គួរឱ្យសង្ស័យជាច្រើនរួមទាំងការបណ្តេញប្រជាជនចេញទាំងបង្ខំ ហើយថ្មីៗនេះត្រូវបានរងការរិះគន់ចំពោះការឧបត្ថម្ភដល់បណ្តាអង្គភាពកងកម្លាំងប្រដាប់អាវុធរបស់ប្រទេសកម្ពុជាទៀតផង។ ចំណុចនេះបានចង្អុលបង្ហាញនូវការកើនឡើងភាពផ្តាច់មុខរបស់ពួកវរជន ក្នុងការលួចប្លន់ធនធានធម្មជាតិ និងបានចម្លងគំរូអំពើពុករលួយ សំណប់និយម និងការរំលោភបំពានសិទ្ធិដែលពីមុនត្រូវបានរកឃើញនៅក្នុងវិស័យព្រៃឈើ និងឧស្សាហកម្មធនធានរ៉ែ។

- ឧស្សាហកម្មបូមខ្សាច់របស់កម្ពុជា បានបង្ករឱ្យមានគ្រោះថ្នាក់ដល់បរិស្ថានឆ្នេរសមុទ្រ ដែលគំរាមកំហែងដល់ប្រភេទពូជងាយរងគ្រោះថ្នាក់ ត្រី និងជីវភាពរស់នៅរបស់ពលរដ្ឋក្នុងមូលដ្ឋាន។ គ្មានភស្តុតាងបង្ហាញថាមានការការពារបរិស្ថានជាមូលដ្ឋាននោះឡើយ។ តែមានការរាយការណ៍ថា មាននាវាជាច្រើនកំពុងតម្លើង និងបូមខ្សាច់ជាញឹកញាប់នៅក្នុងតំបន់ការពារ ដោយគ្មានពិគ្រោះយោបល់ពីមូលដ្ឋានឡើយ។ ទាំងនេះធ្វើឱ្យរដ្ឋាភិបាលចេញបំរាមបូមខ្សាច់នាខែ ឧសភា ឆ្នាំ 2009 ។

- ពាណិជ្ជកម្មនេះ កំពុងនាំមុខដោយ**ប្រទេសសិង្ហបុរី**។ នេះគឺជារដ្ឋដែលនាំចូលខ្សាច់ច្រើនបំផុតក្នុងពិភពលោកនាឆ្នាំ 2008 ។ ប្រទេសនេះបានប្រើប្រាស់ការនាំចូលខ្សាច់ ដើម្បីបង្កើនផ្ទៃដីរបស់ខ្លួនឱ្យបាន 22% គិតចាប់តាំងពីទសវត្សឆ្នាំ 1960 មក។

គម្រោងនេះបានបង្ករការបំផ្លិចបំផ្លាញឆ្នេរសមុទ្រក្នុងតំបន់ ដែលបច្ចុប្បន្ននេះប្រទេសម៉ាឡេស៊ី ប្រទេសវៀតណាម និងប្រទេសឥណ្ឌូនេស៊ី ទាំងអស់គ្នាបានប្រកាសហាមការបូមខ្សាច់សំរាប់ការនាំចេញ ដោយសារមានការបារម្ភផ្នែកបរិស្ថាន។

លោក George Boden ជាឃោសនីអង្គការ Global Witness មានប្រសាសន៍ថា "ស្ថានភាពនេះបានបង្ហាញនូវភាពបរាជ័យជាបន្តបន្ទាប់នៃម្ចាស់ជំនួយអន្តរជាតិសំរាប់ប្រទេសកម្ពុជា ក្នុងការឃ្លាំមើលពួកវរជនមួយចំនួនតូចនៅជុំវិញនាយករដ្ឋមន្ត្រីប៉ុណ្ណោះ"។ គាត់បានមានប្រសាសន៍បន្ថែមទៀតថា "ភោគទ្រព្យធនធានធម្មជាតិរបស់ប្រទេសកម្ពុជាគួរតែអាចលើកស្ទួយជីវភាពប្រជាជន ឱ្យងើបផុតពីភាពក្រីក្របាន។ ផ្ទុយមកវិញជំនួយអន្តរជាតិនេះ បានគាំទ្រដល់សេវាជាមូលដ្ឋាននៅក្នុងប្រទេសកម្ពុជាអស់រយៈកាលជាង 15 ឆ្នាំមកហើយដែលស្មើនឹង 50% នៃថវិការដ្ឋ។ ស្របពេលនេះដែរប្រាក់ចំណូលពីធនធានធម្មជាតិ បានហូរចូលក្នុងគណនីធនាគារឯកជនឯប្រជាជនស្ទើរតែ 70% រស់រានដោយមានប្រាក់ចំណូលតិចជាង 2 ដុល្លារក្នុងមួយថ្ងៃ"។

ការស៊ើបអង្កេតរបស់អង្គការ Global Witness បានតាមដានឃើញនាវាជាច្រើន កំពុងផ្ទុកខ្សាច់ពីក្នុងប្រទេសកម្ពុជា ទៅកាន់គោលដៅរបស់ខ្លួននៅក្នុង**ប្រទេសសិង្ហបុរី**។ ជាមួយនោះដែរ ក៏មានកិច្ចសន្យាជាច្រើនដែលបង្ហាញនូវទំនាក់ទំនងបណ្តាក្រុមហ៊ុនរបស់**ប្រទេសសិង្ហបុរី**ទៅនិងឧស្សាហកម្មខ្សាច់របស់ប្រទេសកម្ពុជាផងដែរ។ នៅក្នុងខែ មិថុនា ឆ្នាំនេះ **ប្រទេសសិង្ហបុរី** នឹងធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំបណ្តាទីក្រុងរបស់ពិភពលោក ដែលជម្រុញឱ្យមាន "ទីក្រុងប្រកបដោយចេរភាព និងរស់រវើក"។

លោក Boden មានប្រសាសន៍ថា "**ប្រទេសសិង្ហបុរី**បាននិយាយថា ការនាំចូលខ្សាច់គឺជាសកម្មភាពពាណិជ្ជកម្មដ៏បរិសុទ្ធមួយ តែវាក៏បង្ហាញខ្លួនឯងថាជាអ្នកនាំមុខក្នុងតំបន់លើបញ្ហាបរិស្ថានផងដែរ"។ គាត់បន្ថែមទៀតថា "បរាជ័យរបស់ប្រទេសក្នុងការសម្រាលចំណាយផ្នែកសង្គម និងអេកូឡូហ្ស៊ីលើការបូមខ្សាច់ បង្ហាញនូវការលាក់ពុតដែលមានទ្រង់ទ្រាយធំ។ ប្រសិនបើ**ប្រទេសសិង្ហបុរី** ឈរលើជំហរការពារបរិស្ថានច្បាស់លាស់នោះ នោះការត្រួតពិនិត្យពីកន្លែងយកប្រភពធនធានខ្សាច់ គឺជាចំណុចដែលត្រូវចាប់ផ្តើម"។

## **បញ្ចប់**

ទំនាក់ទំនង : George Boden តាមរយៈលេខ 0207 492 5899 ឬ 07912 516445 ឬ Oliver Courtney (ជនជាតិបារាំង) តាមរយៈលេខ 0207 492 5848 ឬ 07815 731 889, ocourtney@globalwitness.org.

អង្គការ Global Witness ស៊ើបអង្កេត និងធ្វើយុទ្ធនាការដើម្បីបញ្ឈប់ជម្លោះ និងអំពើពុករលួយពាក់ព័ន្ធនឹងធនធានធម្មជាតិ ព្រមទាំងការរំលោភបំពានបរិស្ថាន និងសិទ្ធិមនុស្សដែលពាក់ព័ន្ធ